ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៥៣៣ / ២៧-០៧-១០

សាលដីកា
លេខ ១៧ "ក្រ III ច" / ២៩-០៣-២០១១

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍ នៅថ្ងៃទី ១០-០៣-២០១១ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជំរះ**

លោកស្រី [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌលេខ ៥៣៣ / ២៧-០៧-២០១០ រវាង :

១-ជនជាប់ចោទឈ្មោះ [redacted] ហុក ភេទប្រុស អាយុ ៤៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅក្រុមទី១ ភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឪពុកឈ្មោះ [redacted] ឈុន "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] ទោសពីមុនគ្មាន ឃុំខ្លួន ៣០-១២-២០០៩ (នៅពន្ធនាគារក្រុងព្រះសីហនុ) ។

-មានមេធាវីការពារលោក [redacted] ចន្ថា ។

ត្រូវជាប់ចោទពីបទ : រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ កាលពីថ្ងៃទី ២៨-១២-២០០៩ បទល្មើសឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ ៣៦ ឆ្នាំ ជាតិខ្មែរ មានទីលំនៅ

[redacted] ។

## រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ២៨-១២-២០០៩ ឈ្មោះ [redacted] ហុក បានចាប់ក្មេងស្រីឈ្មោះ [redacted] លីស ដែលមកលេងនៅក្នុងផ្ទះរបស់ខ្លួន ដាក់នៅលើភ្លៅ លើកចុះលើកឡើងរហូតដល់ប្រដាប់ភេទឡើងរឹង ក៏រូតខោទាញលិង្គចេញយកទៅញលប្រដាប់ភេទលើក្មេងស្រីនោះរហូតដល់ចេញទឹកកាម ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២២ "ឃ" ចុះថ្ងៃទី ២៤-០៥-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលបានសំរេចសេចក្តីដូចខាងក្រោម :

១-កែប្រែកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសពីថ្ងៃទី ២៨-១២-២០០៩ មកកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើស ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ ២០០៩ វិញ ។

២-ផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ [redacted] ហុក ដែលមានសាវតាជាតិដូចខាងលើដាក់ពន្ធនាគារតម្រូវឱ្យធ្វើការរយៈពេល ១៨ឆ្នាំ ពីបទ : រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ ២០០៩ បទល្មើសឱ្យផ្តន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

៣-ឱ្យពិរុទ្ធជនឈ្មោះ [redacted] ហុក សងសំណងជំងឺចិត្តចំនួន ១០លានរៀល ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី ។

-សាលក្រមនេះបានជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៤-០៥-២០១០ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងផ្លូវឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

## នាពេលសវនាការ

### -ប្រធានក្រុមប្រឹក្សាជំនុំជំរះ បានអានរបាយការណ៍សង្ខេបនៃរឿង

-ជនជាប់ចោទឈ្មោះ [redacted] ហុក ( អវត្តមាន )

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ចាន់ធូ ( អវត្តមាន )

-ក្រឡាបញ្ជី បានអានចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹង និងសាក្សី ។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន

មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ លើជនជាប់ចោទ សុំតម្កល់សាលក្រមរបស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល ។

## មេធាវីធ្វើសេចក្ដីសន្និដ្ឋាន

តាមចម្លើយរបស់ជនជាប់ចោទបានឆ្លើយថា កូនក្ដីខ្លួនគ្រាន់តែយកក្មេងស្រី ( ជាជនរងគ្រោះ ) នោះមកដាក់នៅលើភ្លៅ លើកចុះលើកឡើង មិនបានយកប្រដាប់ភេទរបស់ខ្លួនដាក់ចូលទៅក្នុងប្រដាប់ភេទរបស់ជនរងគ្រោះទេ សុំក្រុមប្រឹក្សាជំនុំជំរះពិចារណាតាមច្បាប់ ។

## តុលាការថយទៅពិភាក្សា

ក្រោយពីបានពិនិត្យ ឯកសារក្នុងសំណុំរឿងហើយ ។

ក្រោយពីបានស្ដាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវី ។

ក្រោយពីបានពិភាក្សាត្រឹមត្រូវហើយ ។

## សាលាឧទ្ធរណ៍

## យល់ឃើញថា :

១-បណ្ដឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី ២៨-០៥-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហុក និងសាលក្រមព្រហ្មទណ្ឌលេខ ២២ "ឃ" ចុះថ្ងៃទី ២៤-០៥-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចទទួលជំនុំជំរះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទពិតជាបានរំលោភសេពសន្ថវៈទៅលើកុមារីឈ្មោះ [redacted] ម៉ាលីស ជាច្រើនដងមែន ទោះបីជនជាប់ចោទបដិសេធនៅពេលសវនាការថា មិនបានប្រព្រឹត្តក៏ដោយ ក៏ចម្លើយសារភាពរបស់ជនជាប់ចោទបានឆ្លើយស៊ីសង្វាក់ទៅចម្លើយជនរងគ្រោះក្នុងដំណាក់ការស៊ើបសួរ ។

៣-អំពើ និងសកម្មភាពរបស់ជនជាប់ចោទ គឺជាអំពើអសីលធម៌ មិនចេះគ្រប់គ្រងអារម្មណ៍ បានធ្វើឱ្យក្មេងស្រីម្នាក់មានសតិស្មារតីមិនល្អ នាំគ្នាប្រព្រឹត្តអំពើមិនគប្បី នេះ បើពិនិត្យលើចម្លើយរបស់សាក្សី ម្ដាយជនរងគ្រោះ និងជនរងគ្រោះ ។

៤-ទោះបីជនជាប់ចោទឆ្លើយបដិសេធចម្លើយរបស់ខ្លួន មិនទទួលស្គាល់នូវអំពើល្មើសរបស់ខ្លួនក៏ដោយ ក៏គ្មានសំអាងហេតុ និងភស្តុតាងអ្វីមកដោះបន្ទុក ដែលបណ្ដាលឱ្យមានការសំរាលទណ្ឌកម្មបានឡើយ ។

៥-មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ហុក ពីបទ : រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅភូមិ២ ឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ ២០០៩ បទល្មើសឱ្យផ្ដន្ទាទោសតាមមាត្រា ៥ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃ បទឧក្រិដ្ឋ ប្រាកដមែន ។

៦-សាលក្រមព្រហ្មទណ្ឌលេខ ២២ "ឃ" ចុះថ្ងៃទី ២៤-០៥-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ បានសំរេចសេចក្ដី មានសំអាងហេតុត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ហើយ គប្បីតម្កល់សាលក្រមនេះទុកជាបានការ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៨ ចុះថ្ងៃទី ២៨-០៥-២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ហុក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២២ "ឃ" ចុះថ្ងៃទី ២៤-០៥-២០១០ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការពេញទាំងមូល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] ហុក តាមច្បាប់ ។

៤-សាលដីកានេះជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ១០-០៣-២០១១ ប្រកាសជាសាធារណៈនៅថ្ងៃទី ២៩-០៣-២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ និងមេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងតវ៉ា ក្នុងកំណត់ច្បាប់ ។៕

សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និងកងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះ ឱ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] | ហត្ថលេខា : [redacted] |

បានចំលងត្រឹមត្រូវតាមច្បាប់ដើម

សាលាឧទ្ធរណ៍ ថ្ងៃទី...ខែ....១. ឆ្នាំ ២០១៤

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]